**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះវិហារ**

សំណុំរឿងព្រហ្មទណ្ឌលេខ៣៤២

ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០

សំណុំរឿងជំនុំជម្រះលេខ៤៥៥

ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០

**សាលក្រមព្រហ្មទណ្ឌ**

**លេខ: ១២៨(ខ)**

ចុះថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តព្រះវិហារ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសសាលក្រមនៅថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០២០ នៅសាលាដំបូងខេត្តព្រះវិហារ ដែលមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តព្រះវិហារ

**ចៅក្រមប្រឹក្សា**

-ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តព្រះវិហារ

-លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**តំណាងអយ្យការ**

-លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តព្រះវិហារ។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ:៣៧៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមាន៖

**-ជនជាប់ចោទ៖**

១.ឈ្មោះ [redacted] វណ្ណដា ភេទប្រុស អាយុ២៧ ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូ [redacted] ខេត្តព្រះវិហារ ទីលំនៅមុនពេលឃុំខ្លួនស្ថិតភូមិគូលែនត្បូង ឃុំគូលែនត្បូង ស្រុកគូលែន ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] កេង “ស” ម្តាយឈ្មោះ [redacted] ចាន់ថា “រ” ប្រពន្ធឈ្មោះ [redacted] សុផារី មានកូនចំនួន ១ នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន ។(**ឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២០**)

ជាប់ចោទពីបទ **អំពើលួច (មានស្ថានទម្ងន់ទោស)** និងបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ មាត្រា៣៥៧ ចំណុច២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-បានឃើញដីកាដំណោះស្រាយលេខ៣៨១១/២០២០ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង១៤ និង៣០ នាទី មានករណីលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ស្ថិតនៅភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ បង្កឡើងដោយឈ្មោះ [redacted] វណ្ណដា ហៅ សាន ភេទប្រុស អាយុ២៧ ឆ្នាំ បានធ្វើសកម្មភាពមើលឃើញផ្ទះស្ងាត់ បន្ទាប់មកគាស់បង្អួច រួចយកឈើបុកចំរឹងបង្អួច ចូលទៅក្នុងផ្ទះឃើញម៉ូតូរួចក៏កាច់សោរបន្ទប់ចូលទៅក្នុងបន្ទប់ដេករើយកសំភារៈផ្សេងៗ និងបានយកម៉ូតូ០១ គ្រឿង ទៅបញ្ចាំនៅភ្នំពេញ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនរកហូតបាន ដកហូតថ្នាំញៀនចំនួន០១ កញ្ចប់ ដែលទិញពីឈ្មោះ បូរី ភេទប្រុស អាយុ៣២ ឆ្នាំ រស់នៅភូមិឡូលេខ១ ដើម្បីយកទុកនិងប្រើប្រាស់ដោយខ្លួនឯង ហើយសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

**-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណដា** បានឆ្លើយថា: នៅថ្ងៃកើតហេតុខ្លួនសារភាពពិតជាបានចូលទៅគាស់បង្អួចចូលក្នុងផ្ទះ ហើយលួចយករបស់ក្នុងផ្ទះនោះប្រាកដមែន។ របស់ដែលខ្លួនបានលួចបានមានម៉ូតូម៉ាកហ្វ៊ិច ស៊េរីឆ្នាំ២០១៦ ពណ៌ស ចំនួន ១ គ្រឿង កុំព្យូទ័រចំនួន ១ គ្រឿង គ្រឿងបាស ១ ឈុត និងរបស់របរមួយចំនួនទៀត។ មុនខ្លួនចូលគាស់បង្អួចផ្ទះនេះ ខ្លួនមិនទាន់ស្គាល់ម្ចាស់ឡើយ ទើបពេលសមត្ថកិច្ចឃាត់ខ្លួន ទើបខ្លួនស្គាល់ម្ចាស់ផ្ទះ គាត់ជាគ្រូបង្រៀន ដែលមានមុខដូចក្នុងរូបថតក្នុងសំណុំរឿង។ ការចូលគាស់ផ្ទះនេះ ខ្លួនបានធ្វើសកម្មភាពគាស់តែម្នាក់ឯងប៉ុណ្ណោះ។ ខ្លួនចូលគាស់ផ្ទះពេលព្រឹកវេលាម៉ោងប្រហែល៨ព្រឹក។ ផ្ទះរបស់គាត់ គឺនៅដាច់តែឯង មិនជាប់ផ្ទះអ្នកភូមិណាទេស្ងាត់ល្អ។ មុនឈានដល់ការចូលគាស់នេះ ខ្លួនបានជិះកាត់ផ្ទះនេះរាល់ដងមិនដែលឃើញមនុស្សនៅផ្ទះឡើយ តែងតែបិទទ្វារផ្ទះចោលរហូត។ ក្រោយមកខ្លួនមានគំនិតចូលផ្ទះ ដើម្បីលួចរបស់របរក្នុងផ្ទះ។ លុះដល់ថ្ងៃកើតហេតុ ខ្លួនបានជិះកាត់ផ្ទះនេះ ក៏ឃើញមនុស្សស្រីម្នាក់បានជិះឡានចេញ បន្ទាប់មកខ្លួនបានចូលគាស់នេះ ខ្លួនបានជិះកាត់ផ្ទះនេះក៏ឃើញម្ចាស់ស្រីម្នាក់បានជិះឡានចេញ បន្ទាប់មកខ្លួនបានចូលគាស់បង្អួចចូលក្នុងផ្ទះដើម្បីលួចតែម្តង។ ចំពោះរបស់របរខ្លួនលួចបានក្រៅពីម៉ូតូ ខ្លួនមិនទាន់លក់ទេ ហើយម្ចាស់ក៏ទទួលបានវិញដែរ។ ចំណែកម៉ូតូខ្លួនយកទៅបញ្ចាំនៅភ្នំពេញបានប្រាក់៤០០ ដុល្លារ។ ចំពោះថ្នាំញៀននេះ ខ្លួនបានទិញពីភ្នំពេញមក។ ថ្នាំញៀននេះខ្លួនបានទិញយកប្រើប្រាស់តែប៉ុណ្ណោះ។ ខ្ញុំបាទមិនបានលក់បន្តឡើយ ឬចែកចាយថ្នាំញៀនទេ។

**-តាមអំណានចម្លើយរបស់ឈ្មោះ [redacted] ឌីណា** បានឆ្លើយថា៖កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ៧ និង ១០ នាទី ខ្លួនមានប្រជុំនៅសាលាបឋមសិក្សាឈានមុខ ដោយសារមេឃភ្លៀង និងត្រូវទៅបង្រៀនសិស្សនៅទល់ មុខផ្សារកំពង់ប្រណាកផង ខ្លួនក៏ទុកម៉ូតូនៅផ្ទះរួចជិះឡានរបស់ប្អូនទៅមុនចេញពីផ្ទះខ្លួនបានចាក់សោរទ្វារបង្អួចទាំងអស់។ លុះដល់ម៉ោង០១ និង ៣០ នាទីរសៀល ខ្លួនក៏ត្រឡប់មកវិញឃើញក្តារបន្ទះ

ដែលខ្លួនដាក់សម្រាប់ដាក់ ម៉ូតូចុះពីផ្ទះនៅលើនឹងជណ្ដើរផ្ទះ ហើយខ្លួនបានដើរទៅបើកទ្វារបើកសោរក្នុងផ្ទះឃើញម៉ូតូចំណែកបង្គួចមានស្នាមគាស់និងបាត់របស់របរជាច្រើនទៀត។ ប្រហែលជាម៉ោង ៣ ខ្លួនបានដាក់ពាក្យបណ្ដឹងទៅប៉ូលីស។ ពេលនេះខ្លួនបានទទួលទ្រព្យសម្បត្តិរបស់ខ្លួនមកវិញហើយ ខ្លួនសម្រេចចិត្តលះបង់ប្ដឹងហើយ។

-តាមអំណានកំណត់ហេតុទទួលវត្ថុតាងលេខ៨៤/២០ ចុះថ្ងៃទីដប់ប្រាំមួយ ខែកញ្ញា ឆ្នាំ២០២០ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះវិហារមានដូចជា៖ ម្សៅក្រាមពណ៌សថ្លា ទម្ងន់0,0៩ ក្រាម , ម៉ូតូសង់កូរ៉េ (បាញ់ថ្នាំខ្មៅ) ពាក់ស្លាកលេខ ព្រះវិហារ 1A-3949 ចំនួន០១ គ្រឿង (ចាស់គ្មានសោ) , ទូរស័ព្ទអាក ណូគា ពណ៌ខ្មៅលាយខៀវ ចំនួន ១ គ្រឿង(ចាស់) ទូរស័ព្ទដៃខូចចំនួន ២ គ្រឿង និងសំបកទូរស័ព្ទមួយចំនួនទៀត , លុយខ្មែរចំនួន ១៨,២០០ (មួយម៉ឺនប្រាំបីពាន់ពីរយ)រៀល លុយដុល្លារ ២ (ពីរ) ដុល្លារ លុយឡាវចំនួន ៥0,000 (ប្រាំម៉ឺនគីប) កាបូបដៃប្រុសពណ៌សូកូឡាចំនួន១ , កាត ABA ចំនួន១ , កាតគ្រីម៉ូតូចំនួន២ , អាវប៉ារ៉ាចំនួន ២ និងខោប៉ារ៉ាចំនួន ៤ ខោ , កាបូបស្ពាយក្រោយពណ៌ខ្មៅចំនួន ០១ , កន្ត្រៃយ៍ចំនួន ៣ ,មួលវីសចំនួន ០៣ , ដង្កាប់ចំនួន០១ ,សោរម៉ូតូចំនួន២ ,កូនសោរមួយចំនួនទៀត , ដំបងឈើប្រវែងប្រហែល១,៥៥ ម៉ែត្រចំនួន០១ និងឧបករណ៍ជក់គ្រឿងញៀនមួយចំនួន។

**-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋាន:** ក្រោយពីបានស្ដាប់កិច្ចពិភាក្សាដេញដោលនាពេលសវនាការរួចមកឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់ប្រាកដមែន ។ហេតុដូចនេះតំណាងអយ្យការសម្រេចរក្សាបទចោទប្រកាន់ទុកជាបានការដដែល និងសុំឱ្យតុលាការ សម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារតាមបញ្ញត្តិច្បាប់។

**-មេធាវីរបស់ជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានការពារ៖** ក្រោយពីបានស្ដាប់កិច្ចពិភាក្សាដេញដោល រួចមកឃើញថាកូនក្ដីរបស់ខ្លួនបានសារភាពទទួលស្គាល់អំពើនិង កំហុសរបស់ខ្លួនដោយឥតមានលាក់លៀមនាពេលសវនាការ ។ហេតុដូចនេះក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។ ខ្លួនស្នើសុំឱ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចផ្ដន្ទាទោសលើកូនក្ដីរបស់ខ្លួនដោយផ្ដល់នូវស្ថានសម្រាលទោស។

**-ជនជាប់ចោទធ្វើការសំណូមពរចុងក្រោយ៖** សូមឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសចំពោះខ្លួនផង ព្រោះខ្លួនដឹងកំហុសហើយ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌នាពេលសវនាការ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ឈ្មោះ ប៊ុត ឌីណា នាពេលសវនាការ

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវី

## ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ
## សាលាដំបូងខេត្តព្រះវិហារ យល់ឃើញថា

-តាមដីកាដំណោះស្រាយលេខ៣៨១១/២០២០ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ សម្រេចបញ្ជូនជនត្រូវចោទ៖



Scanned with CamScanner

ឈ្មោះ [redacted] វណ្ណដា ភេទប្រុស អាយុ២៧ ឆ្នាំ សញ្ជាតិខ្មែរ(មានសាវតាជាតិដូចខាងលើ) ទៅជំនុំជម្រះពីបទ **អំពើលួច** (មានស្ថានទម្ងន់ទោស) និងបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា៣៥៧ **ចំណុច២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

-តាមចម្លើយរបស់ជនជាប់ចោទ, មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងដែលមាននៅក្នុងសំណុំរឿងឃើញថាមានភាពស៊ីចង្វាក់គ្នា បញ្ជាក់បានថាពិតជាមាននូវ**អំពើលួច (មានស្ថានទម្ងន់ទោស)** និង **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ដែលបង្កឡើងដោយ ជនជាប់ចោទឈ្មោះ [redacted] **វណ្ណដា** ភេទប្រុស អាយុ២៧ ឆ្នាំ សញ្ជាតិខ្មែរ(មានសាវតាជាតិដូចខាងលើ) ប្រាកដមែន។ អំពើនេះល្មើសទៅនឹងមាត្រា**៣៥៣** មាត្រា៣៥៧ **ចំណុច២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

-មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **វណ្ណដា** ភេទប្រុស អាយុ២៧ ឆ្នាំ សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ពីបទ**អំពើលួច (មានស្ថានទម្ងន់ទោស)** និង **ប្រើប្រាស់ដោយ ខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣ មាត្រា៣៥៧** ចំណុច២ **នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

-គ្មានភស្តុតាងណាបញ្ជាក់ថាជនជាប់ចោទជាជនវិកលចរិក ឬវិបល្លាសស្មារតីឡើយ។ ផ្ទុយទៅវិញជនជាប់ចោទជាបុគ្គលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។

-ការតម្កល់បទចោទប្រកាន់របស់តំណាងអយ្យការតាមការធ្វើសេចក្តីសន្និដ្ឋាននៅក្នុងពេលសវនាការ គប្បីតុលាការពិចារណាសម្រេច។

-ការប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **វណ្ណដា** ដោយសារតែភាពអវិជ្ជា និងជាប្រព្រឹត្តបទល្មើសលើកទី១ នាពេលសវនាការជនជាប់ចោទបានឆ្លើយសារភាពកំហុស និងទទួលស្គាល់នូវអំពើប្រព្រឹត្តរបស់ខ្លួន។ ស្ថានភាពទាំងនេះ គប្បីតុលាការពិចារណាសម្រេចផ្តន្ទាទោសលើជនជាប់ចោទដោយផ្តល់នូវស្ថានទម្រាលទោសតាមបញ្ញត្តិ**មាត្រា៩៣ មាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ**។

-វត្ថុតាងដែលបានចាប់យកមានដូចជា៖ក្រាមពណ៌សថ្លា ទម្ងន់0,0៩ ក្រាម , ម៉ូតូសង់ហ្គូរ៉េ(បាញ់ថ្នាំខ្មៅ) ពាក់ស្លាកលេខ ព្រះវិហារ 1A-3949 ចំនួន០១ គ្រឿង (ចាស់គ្មានសោ) , ទូរស័ព្ទម៉ាក ណូគា ពណ៌ខ្មៅលាយខៀវ ចំនួន ១ គ្រឿង(ចាស់) ទូរស័ព្ទដៃខូចចំនួន ២ គ្រឿង និងសំបកទូរស័ព្ទមួយចំនួនទៀត , លុយខ្មែរចំនួន ១៨,២០០ (មួយម៉ឺនប្រាំបីពាន់ពីររយ)រៀល លុយដុល្លារ ២ (ពីរ) ដុល្លារ លុយឡាវចំនួន ៥0,000 (ប្រាំម៉ឺនគីប) កាបូបដៃប្រុសពណ៌ស្វូក្កូឡាចំនួន១ , កាត ABA ចំនួន១ , កាតគ្រីម៉ូតូចំនួន២ , អាវប៉ាវ៉ាចំនួន ២ និងខោប៉ាវ៉ាចំនួន ៤ ខោ , កាបូបស្ពាយក្រោយពណ៌ខ្មៅចំនួន ០១ , កន្ត្រៃយ៍ចំនួន ៣ ,ទុលវីសចំនួន ០៣ , ដង្កាប់ចំនួន០១ ,សោរម៉ូតូចំនួន២ ,កូនសោរមួយចំនួនទៀត , ដំបងឈើប្រវែងប្រហែល១,៥៥ ម៉ែត្រចំនួន០១ និង ឧបករណ៍ជក់គ្រឿងញៀនមួយចំនួន។ គប្បីតុលាការពិចារណាសម្រេចរឹបអូស។

-ការសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនៅក្នុងពេលសវនាការ។ គប្បីតុលាការពិចារណាសម្រេច។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណដា បានសំណូមពរចុងក្រោយថា សូមឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសចំពោះខ្លួនផង ព្រោះខ្លួនដឹងកំហុសហើយ គប្បីតុលាការពិចារណា។

**ហេតុដូច្នេះសាលាដំបូងខេត្តព្រះវិហារ**

**វិនិច្ឆ័យសេចក្តី**

**១.ផ្តន្ទាទោសជនជាប់ចោទ៖**

-ឈ្មោះ [redacted] វណ្ណដា ភេទប្រុស អាយុ២៧ ឆ្នាំ សញ្ជាតិខ្មែរ (**ដែលមានសារគាជាតិ ដូចខាងលើ**) ដាក់ពន្ធនាគារ កំណត់រយៈពេល០១(**មួយ**) **ឆ្នាំ** និង ០៦ (**ប្រាំមួយ**) **ខែ** ពីបទ **អំពើលួច** (**មានស្ថានទម្ងន់ទោស**) និងបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៣៥៣ មាត្រា៣៥៧ ចំណុច២ នៃក្រមព្រហ្មទណ្ឌ **និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៩៣ មាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ។**

**២.វត្ថុដែលចាប់យកមានដូចជា៖**

- ក្រាមពណ៌សថ្លា ទម្ងន់០,០៩ ក្រាម និងឧបករណ៍ជក់គ្រឿងញៀន មួយចំនួនត្រូវរឹបអូសបំផ្លាញចោល។
- ម៉ូតូសង់កូវ៉េ(បាញ់ថ្នាំខ្មៅ) ពាក់ស្លាកលេខ ព្រះវិហារ 1A-3949 ចំនួន០១ គ្រឿង (ចាស់គ្មានសោ) , ទូរស័ព្ទម៉ាកណូគា ពណ៌ខ្មៅលាយខៀវ ចំនួន ១ គ្រឿង(ចាស់) ទូរស័ព្ទដៃខូចចំនួន ២ គ្រឿង និងសំបកទូរស័ព្ទមួយចំនួនទៀត , លុយខ្មែរចំនួន ១៨,២០០ (មួយម៉ឺនប្រាំបីពាន់ពីរយ)រៀល លុយដុល្លារ ២ (ពីរ) ដុល្លារ លុយឡាវចំនួន ៥០,០០០ (ប្រាំម៉ឺនគីប) កាបូបដៃប្រុសពណ៌ស្ទូកូឡាចំនួន១ , កាត ABA ចំនួន១ , កាតគ្រីម៉ូតូចំនួន២ , អាវប៉ារ៉ាចំនួន ២ និងខោប៉ារ៉ាចំនួន ៤ ខោ , កាបូបស្ពាយក្រោយពណ៌ខ្មៅចំនួន ០១ , កន្រ្តៃប៍ចំនួន ៣ ,ទុលវីសចំនួន ០៣ , ដង្កាប់ចំនួន០១ ,សោរម៉ូតូចំនួន២ ,កូនសោរមួយចំនួនទៀត , ដំបងឈើប្រវែងប្រហែល១,៥៥ ម៉ែត្រចំនួន០១ ត្រូវរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ **ខែធ្នូ ឆ្នាំ២០២០** និងប្រកាសជាសាធារណៈនៅថ្ងៃទី**២៤ ខែធ្នូ ឆ្នាំ២០២០** ដោយចំពោះមុខជនជាប់ចោទ។

បើភាគីពាក់ព័ន្ធមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ គឺមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍១០កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ព្រះវិហារ,ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជី**

[redacted]



[redacted]

Scanned with CamScanner